**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងព្រះសីហនុ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១៣១ ចុះថ្ងៃទី ០៥
ខែ កក្កដា ឆ្នាំ ២០០៤

<u>សាលក្រម</u>
លេខ ៥៨ ចុះថ្ងៃទី ១៦
ខែ វិច្ឆិកា ឆ្នាំ ២០០៤

សាលក្រមនេះចូលស្ថាពរហើយ
ក្រុងព្រះសីហនុ,ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី [redacted]

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក **គៀង សុន្ទរោ** ជាក្រឡាបញ្ជីសវនាការ

**<u>មេធាវី</u>**

លោក [redacted]ធី

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣១ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទ :

-**អ ជ** ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឬស្សីស្រុក ឃុំឬស្សីស្រុក ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅសព្វថ្ងៃក្រុម៣ ភូមិអូរឧកញ៉ាហេង សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ីធ្វើស្រែ ឪពុកឈ្មោះ **អ គ** ( **រ** ) ម្តាយឈ្មោះ **ម ឃ** ( **រ** ) ប្តីឈ្មោះ **ស គ** មានកូន ០៨នាក់ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

-ជាប់ចោទពីបទ " **<u>បង្ករបួសដោយចេតនា</u>** " ប្រព្រឹត្តនៅភូមិអូរឧកញ៉ាហេង សង្កាត់ អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ម ចជ** ភេទស្រី អាយុ ៣៧ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅក្រុម៣ ភូមិអូរឧកញ៉ាហេង សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាជនរងគ្រោះ ។

-ឈ្មោះ **ឌ ៩** ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ីកងការពារកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ មានទីលំនៅក្រុម៨ ភូមិ៤ សង្កាត់ ៤ ខណ្ឌមិត្តភាព

ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៧៣ ដសព ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១០៧៥ តព ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១០៧៨ ត.ព ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ឯរឿងហេតុមានដូចតទៅ :

-កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ វេលាម៉ោង ១៧ និង ៣០នាទី ឈ្មោះ **ម ចជ** បានបាត់មាន់ក៏ដើរទៅរកដល់ផ្ទះ ឪ **៩** ដែលកំពុងតែធ្វើត្រី ដោយនៅដៃរបស់គាត់មានកាំបិត ពេល **ម ចជ** សួរនាំទៅឈ្មោះ **អ ៩** ស្មានតែឈ្មោះ **ម ចជ** មានគំនិតអាក្រក់មកលើខ្លួន ក៏យកកាំបិតដែលបានកាន់នៅនឹងដៃកាប់ទៅលើឈ្មោះ **ម ចជ** ជាច្រើនកាំបិត បណ្តាលឱ្យឈាម និង របួសជាច្រើនកន្លែង ហើយសន្លប់ក៏ត្រូវបានអ្នកជិតខាងជួយចាប់ និង អន្តរាគមន៍ ឈ្មោះ **ម ចជ** ក៏ត្រូវបានបងប្អូនយកទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ឈ្មោះនេះក៏ត្រូវពិការដៃខាងស្តាំដែលប្រើការមិនកើតដល់សព្វថ្ងៃ ។ ឯឈ្មោះ **អ ៩** ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយ ឈ្មោះនេះក៏រត់គេចខ្លួនរហូតដល់ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៤ ទើបសមត្ថកិច្ចចាប់ខ្លួនបាន ។

## នាពេលសវនាការ

-ឈ្មោះ **អ ៩** ជាជនជាប់ចោទបានឆ្លើយថា កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ វេលាម៉ោងដប់ប្រាំពីរខ្លួនកំពុងតែធ្វើត្រី ក៏ឃើញឈ្មោះ **ម ចជ** មកដល់ផ្ទះខ្លួន ក៏សួររកមាន់ គាត់ថា មាន់គាត់បាត់ ហើយរត់មកផ្ទះខ្លួនហ៊ីងខ្លួនមិនដឹងជាមានអ្វីមកទាញខ្លួនឱ្យកាន់កាំបិតកាប់ទៅលើឈ្មោះ **ម ចជ** ជាច្រើនកាំបិត ក៏ឃើញមានឈាមហូរខ្លួនទំលាក់កាំបិតចោល ហើយរត់ទៅទិសខាងកើត គឺនៅសំរាកក្នុងភូមិកោះខ្យង លុះព្រឹកឡើងសមត្ថកិច្ចចាប់ខ្លួនបាន ។ ខ្លួនសុំបញ្ជាក់ថា មូលហេតុដែលខ្លួនហ៊ានកាប់ឈ្មោះ **ម ចជ** នេះ គឺពីមុនមកឪពុកខ្លួនបានទុកកាក់មួយ ឱ្យខ្លួនថែរក្សាខ្លួនបានបង្ហាញឱ្យ **ម ចជ** មើលម្តងរួចមកហើយ ដល់ពេល **ម ចជ** មករកមាន់គាត់ ខ្លួនមានអារម្មណ៍ខ្លាចក្រែងគាត់យកកាក់ខ្លួន ខ្លួនក៏កាប់គាត់តែម្តងទៅ ហើយកន្លងមកខ្លួន និង **ម ចជ** មិនដែលមានទំនាស់គ្នាម្តងណាទេ ។

-ឈ្មោះ **ម ចជ** ជាជនរងគ្រោះបានឆ្លើយថា កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ វេលាម៉ោង ១៧ និង៣០នាទី ពេលខ្លួនត្រឡប់មកពីស៊ីឈ្នួលដាំស្មៅឱ្យគេ ខ្លួនបានឮកូនខ្លួនថា បាត់មាន់ ខ្លួនក៏ដើរទៅរកមើលនៅផ្ទះ **អ ៩** មិនបានសួរនាំអ្វីផង ស្រាប់តែឈ្មោះ **អ ៩** មិននិយាយអ្វីទាំងអស់ ក៏ឃើញទាញកាំបិតចែតមកកាប់ខ្លួនស្ទើរត្រូវគ្រប់កន្លែង ខ្លួនក៏រត់គេច ហើយដួលសន្លប់តែម្តង ពេលដឹងខ្លួននៅមន្ទីរពេទ្យ សរុបដែលគាត់កាប់ខ្លួនចំនួន ១១កាំបិត គឺត្រូវដៃសងខាងចំនួន ០២កាំបិត ក្បាល ០៤កាំបិត មុខពីរកាំបិត និង ដោះមួយកាំបិតទៀត ។ ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់ចំពោះជនល្មើស និង សុំទាមទារសំណងថ្លៃព្យាបាលរបួសចំនួន ៣.០០០ដុល្លាសហរដ្ឋអាមេរិក "បីពាន់ដុល្លាសហរដ្ឋអាមេរិក" តែទុកលទ្ធភាពឱ្យឈ្មោះ **ឧ ៩** ជាបងជាអ្នកទាមទារសំណងទៅចុះ ។

-តាមការអានចម្លើយរបស់ឈ្មោះ **ឧ ៩** ជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា នៅថ្ងៃកើតហេតុ គឺខ្លួនមិនបាននៅផ្ទះប្អូនស្រីខ្លួនទេ គឺនៅផ្ទះខ្លួន ក៏បានទទួលទូរស័ព្ទពីអ្នកជិតខាងថា ប្អូនស្រីខ្លួនត្រូវរបួស ហើយខ្លួនប្រាប់ទៅ

វិញថា បើវានៅដង្ហើមឱ្យនាំវាទៅមន្ទីរពេទ្យ ខ្លួនទៅរង់ចាំនៅទីនោះមុន គឺពេទ្យចំការចេក ។ ចំពោះសំណងថ្លៃថ្នាំព្យាបាលរបួសខ្លួនទាមទារចំនួន ១០លានរៀល ដោយពិនិត្យឃើញថា ប្អូនស្រីខ្លួនពិការដៃស្តាំ មានកូនដល់ទៅ ០៨នាក់ គ្មាននរណារកស៊ីចិញ្ចឹមទេ ចំពោះទណ្ឌកម្មទុកលទ្ធភាពឱ្យតុលាការចុះ ។

-ឈ្មោះ ៩ សត ជាសាក្សីបានឆ្លើយថា ខ្លួនមានផ្ទះនៅជាប់ និង ជនរងគ្រោះ និង ជនជាប់ចោទដែរ នៅថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ វេលាម៉ោង ០៦ជាងល្ងាច ខ្លួនកំពុងតែដាំបាយ ក៏ស្រាប់តែឃើញ ឃ ចជ រត់មកដល់របងជាប់ផ្ទះខ្លួន ហើយស្រែកឱ្យខ្លួនជួយ ខ្លួនក៏ឃើញមានឈាមហូរពេញក្បាល ពេញខ្លួនទាំងអស់ខ្លួនក៏គ្រានាំគាត់មកផ្ទះខាងមុខផ្លូវថ្នល់ ហើយគាត់ប្រាប់ថា ឈ្មោះ ជ ឃ ហៅ អា ស ជាអ្នកកាប់គាត់ ខ្លួន និង អ្នកជិតខាងក៏នាំគាត់មកមន្ទីរពេទ្យចំការចេក ឯជនល្មើសរត់គេចខ្លួន ក្រោយមកក៏សមត្ថកិច្ចចាប់ខ្លួនបានជនល្មើស ហើយរឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនមិនបានដឹងឡើយ ។

-បានឃើញលិខិតកោសល្យវិច័្ឆយលេខ ១១ មព.កសន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៤ របស់មន្ទីរសុខាភិបាល ក្រុងព្រះសីហនុ ដែលបានបញ្ជាក់ពីមុខរបួស និង ការសន្និដ្ឋានរួមដូចខាងក្រោម :

១-របួសនៅត្រង់ Parietale gauche រាងទ្រវែង បណ្តោយ ១០សម ខ ១សម ជម្រៅដល់លលាដ៍ឆ្អឹង ។

២-របួសនៅត្រង់ Occipitale ២ កន្លែង :

-គុម្ពត្រចៀកខាងឆ្វេងមានទំហំ ៨សម x ២សម ជម្រៅដល់ឆ្អឹង ។

-ចំពីក្រោយមានបណ្តោយ ១០សម រាងជាអង្កត់ធ្នូជម្រៅដល់លលាដ៍ឆ្អឹង ។

៣-របួសនៅថ្ពាល់ខាងឆ្វេងមានប្រវែង ១០សម x ១សម ជម្រៅ ០.៥សម ។

៤-របួសនៅដើមដៃឆ្វេងផ្នែកខាងក្រៅ ( face externe ) រាងទ្រវែងមានបណ្តោយ ៨សម x ០.៣សម ។

៥-របួសនៅកំភួនដៃស្តាំ ២ កន្លែង

-នៅចំកណ្តាលកំភួនដៃផ្នែកខាងក្នុង ( Face interne ) រាងពងក្រពើមានបណ្តោយ ៨សម x ៤សម ជម្រៅដល់ឆ្អឹង ។

-ចំងាយពីកដៃ ០៥សម ផ្នែកខាងក្រៅរាងពងក្រពើមានបណ្តោយ ៥សម x ៤សម ជម្រៅដល់ឆ្អឹង ។

៦-របួសនៅជោះខាងឆ្វេងរាងទ្រវែងមានបណ្តោយ ៥ សម x ០.៥សម ជម្រៅ ០.៥សម ។

**ការសន្និដ្ឋាន** : គឺរបួសបានជាសះស្បើយពិនិត្យនៅ ១៩ ខែ សីហា ឆ្នាំ ២០០៤ ជាលើកទី ២

-ប៉ុន្តែបន្សល់នៅស្នាកស្នាម និង ពិការភាពដៃស្តាំ ( ដៃស្តាំត្រូវបានបាត់បង់សមត្ថភាព ) ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤ ដែលបានទទួលវត្ថុតាងពីនគរបាលក្រុងព្រះសីហនុ រួមមាន :

-កាំបិតចែតចំនួន ០១

-ស្បែកជើងផ្ទាត់ចំនួន ០១គូ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ អ ជ ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅសង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុដូច្នេះសុំឱ្យលោកចៅក្រមជំនុំជំរះមេត្តាវិនិច្ឆ័យទៅតាមច្បាប់ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនបានកាប់ទៅលើជនរងគ្រោះនេះ គឺមកពីជនជាប់ចោទមានរបស់អ្វីដែលមើលមិនឃើញមកអូសស្មារតីរបស់គាត់ លែងដឹងពីអ្វីស្មានតែខ្មោច គាត់ចេះតែកាប់ៗមិនដឹងពីជនរងគ្រោះឡើយ តែបើគាត់មានស្មារតីរឹងប៉ឹងវិញនោះ ក៏គាត់មិនប្រព្រឹត្តអំពើយ៉ាងដូច្នេះដែរ នេះហាក់បីដូចជាមានខ្មោចបិសាចចូលខ្លួនគាត់អ៊ីចឹង ។ ម្យ៉ាងទៀតជនជាប់ចោទមានកូនទៅដល់ ០៨នាក់ ពឹងផ្អែកលើកំលាំងម្តាយនៅថែទាំមើលកូនតូចៗ នៅតែឪពុកម្នាក់មិនអាចទប់ទល់ក្នុងជីវភាពគ្រួសារបានទេ មួយចំណែកទៀតកូនក្តីខ្លួននេះគ្មានចេះអក្សរទាល់តែសោះ ការធ្វើយ៉ាងដូច្នេះគ្មានបានពិចារណាអ្វីនោះទេ ហេតុនេះសុំឱ្យចៅក្រមជំនុំជំរះមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផងដោយអនុគ្រោះ ។

-ជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនមានការសោកស្តាយកំហុសរបស់ខ្លួន ខ្លួនសន្យាថាឈប់ប្រព្រឹត្តអំពើយ៉ាងដូច្នេះទៀតហើយ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ការអានចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្នុងព្រះនាម

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមការអះអាងរបស់ជនជាប់ចោទដែលបានលើកឡើងថា ការយកកាំបិតទៅកាប់ជនរងគ្រោះនេះ គឺដោយសារមានគេ ‹ ខ្មោច › អូសទាញឱ្យកាប់ ប្រសិនជាមិនមានគេអូសទាញទេ មិនអាចកាប់មានមុខរបួសដល់ទៅចំនួន ១១ កន្លែងនោះដែរ ចម្លើយនេះ គឺការឆ្លើយទម្លាក់ទៅលើខ្មោច ដើម្បីឱ្យរួចទោស ឬ ស្រាលប៉ុណ្ណោះ ។

-គ្រាន់តែជនរងគ្រោះសួររកមាន់ ដែលគាត់ធ្លាប់បាត់កន្លងមក ជនល្មើសនឹកស្មានថា ជនរងគ្រោះចោទប្រកាន់លើគាត់ ឬ ក៏ជនល្មើសធ្លាប់ចាប់មាន់គេយកទៅហូបជារឿងរាល់លើក នឹកឃើញរាងរអៀសខ្លួន ម្យ៉ាងទៀតជនល្មើសខ្លាចជនរងគ្រោះយកកាក់ដែលរន្សល់ទុកពីឪពុកគេផង ក៏ប្រើអំពើហិង្សាទៅលើជនរងគ្រោះតែម្តង ហើយកាប់ផ្តួនគ្មានញញើតដៃ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទទៅលើជនរងគ្រោះ គឺសាហាវណាស់ ។ មនុស្សមិនដែលធ្លាប់មានទំនាស់និងគ្នារស់នៅក្នុងភូមិផងជាមួយគ្នា គួរពេលសែតែយោគយល់គ្នាទៅវិញទៅមក ស្រឡាញ់រាប់អានគ្នា តែជនល្មើសមិនគិតយ៉ាងដូច្នេះឯណា គិតតែពីកាប់ៗ ដើម្បីសំរេចក្តុងគោលបំណងរបស់ខ្លួនតែប៉ុណ្ណោះ ។

-ជនរងគ្រោះត្រូវរងរបួសជាច្រើនកន្លែង គឺចំនួន ១១កន្លែង រហូតដល់ពិការដៃស្តាំអស់មួយជីវិត ដែលមិនអាចប្រើការបាន ។

-វត្ថុតាងមានកាំបិតដែលជាវត្ថុរឹង ហើយមុតដែលជនល្មើសបានប្រើនោះ គឺជាអាវុធដែលអាចនាំឱ្យមានគ្រោះថ្នាក់ ដូច្នេះកិរិតទណ្ឌកម្ម ក៏ត្រូវតែអនុវត្តទ្វេមួយជាពីរដែរ ។ ដោយឡែកទ្រនាប់ជើងពេលជនល្មើសពាក់រត់ទៅមិនមែនជាវត្ថុល្មើសក្នុងការប្រព្រឹត្តនោះទេ ។

-លិខិតកោសល្យវិច្ឆ័យរបស់មន្ទីរសុខាភិបាលក្រុងព្រះសីហនុ មានមូលដ្ឋានគ្រប់គ្រាន់ តុលាការយកជាការបាន ។

-បណ្តឹងទាមទារសំណងថ្លៃព្យាបាលរបួស និង ជម្ងឺចិត្តជនរងគ្រោះ និង ដើមបណ្តឹងមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាដល់បញ្ហានេះ ។

-ចម្លើយសាក្សីមានមូលដ្ឋានច្បាស់លាស់គួរឱ្យតុលាការជឿបាន ។

-ជនជាប់ចោទ ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង មានកិរិតវប្បធម៌ទាប. មានកូននៅក្នុងបន្ទុកជនជាប់ចោទមិនបានត្រិះរិះពិចារណាឱ្យបានវែងឆ្ងាយក្នុងការប្រព្រឹត្តនោះដែរ ។ ជនជាប់ចោទទទួលស្គាល់នៅកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ហើយមានការសោកស្តាយយ៉ាងខ្លាំងនូវអំពើរបស់ខ្លួនកន្លងមកទៅលើជនរងគ្រោះនោះ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ អ ជ ភេទស្រី ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ

## សំរេច :

១-ឈ្មោះ អ ជ ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ ០៣ឆ្នាំ ( បីឆ្នាំ ) គិតចាប់ពីថ្ងៃចាប់ខ្លួន ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៤ ។

ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិអូរឧកញ៉ាហេង សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ អ ជ សងសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ១០.០០០.០០០រៀល ( ដប់លានរៀល ) ទៅជនរងគ្រោះឈ្មោះ ឃ ចជ ដែលមានឈ្មោះ ជ ជ ជាដើមបណ្តឹងរដ្ឋប្បវេណី គិតចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-វត្ថុតាងរួមមានកាំបិតចែតចំនួន ០១ ត្រូវរឹបអូស និង បំផ្លាញចោល ដោយឡែកទ្រនាប់ជើងផ្ទាត់ ០១គូ ត្រូវប្រគល់ឱ្យជនជាប់ចោទវិញនៅពេលផុតទណ្ឌកម្ម ។

៤-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ជនរងគ្រោះ កំបាំងមុខ ដើមបណ្តឹង បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

**ក្រឡាបញ្ជី** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]